តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL Cambodia

# ស្តង់ដារធុរកិច្ចអន្តរជាតិស្តីពីការប្រឆាំងនឹងការសូកប៉ាន់

ឯកសារនេះពិនិត្យមើលលើស្តង់ដារអន្តរជាតិ ដែលមានស្រាប់ទាក់ទងនឹងការប្រឆាំងនឹងការសូកប៉ាន់និងបង្ហាញពីទិដ្ឋភាពទូទៅអំពីអត្ថប្រយោជន៍ និងបញ្ហាប្រឈមក្នុងការរួមបញ្ចូលស្តង់ដារទាំងនេះទៅក្នុងការអនុវត្តធុរកិច្ចនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ។ ករណីសិក្សាក្នុងតំបន់ដែលទទួលបានជោគជ័យក្នុងការបញ្ចូលស្តង់ដារទាំងនេះក៏នឹងលើកយកមករៀបរាប់បង្ហាញនៅក្នុងឯកសារនេះផងដែរ ។

## គោលបំណង

អង្គការស្តង់ដារអន្តរជាតិ (ISO) បានកំណត់និយមន័យស្តង់ដារថាជា "ឯកសារដែលផ្តល់នូវតម្រូវការ លក្ខណៈភិនភាគ គោលការណ៍ណែនាំ ឬលក្ខណៈសម្បត្តិ សម្រាប់ប្រើប្រាស់ទូទៅដើម្បីធានាថា សម្ភារៈ ផលិតផល ដំណើរការ និងសេវាកម្មមានលក្ខណៈសមស្របទៅនឹងគោលបំណង ។" នៅក្នុងបរិបទនៃឯកសារនេះ ស្តង់ដារធុរកិច្ចអន្តរជាតិគឺជាមូលដ្ឋាន្លូវការដែលក្រុមហ៊ុនអាចប្រើប្រាស់សម្រាប់ជួយក្នុងការរៀបចំប្រព័ន្ធប្រតិបត្តិតាម។ ស្តង់ដារទាំងនេះអាចបត់បែនបានតាមកាលៈទេសៈ និងមានប្រភេទនិងទំហំខុសពីគ្នាអាស្រ័យតាមតម្រូវការផ្សេងៗគ្នារបស់ក្រុមហ៊ុននីមួយៗ ។ ក្រុមហ៊ុនអាចប្រើប្រាស់ស្តង់ដារក្នុងស្រុកដែលអនុលោមតាមច្បាប់ក្នុងប្រទេស ឬច្បាប់នៅប្រទេសដទៃផ្សេងទៀតបើសិនជាមានប្រតិបត្តិការ ឬទំនាក់ទំនងធុរកិច្ចក្រៅប្រទេស ។

ការអនុវត្តប្រព័ន្ធប្រតិបត្តិតាមនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ជាពិសេសចំពោះសហគ្រាសធុនតូចនិងមធ្យម (SME) នៅមានកម្រិតនៅឡើយ ។

យោងតាមរបាយការណ៍អង្គការតម្លាភាពកម្ពុជាស្តីពីការយល់ឃើញពីអំពើពុករលួយនៅក្នុងសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជាឆ្នាំ ២០១៥ បានឱ្យដឹងថា ៦៣% នៃនាយកប្រតិបត្តិក្រុមហ៊ុនមិនដែលលើកយកសុចរិតភាពធុរកិច្ចមកពិភាក្សា នៅក្នុងក្រុមហ៊ុនឡើយ បើទោះបីជា ៤៧% នៃនាយកប្រតិបត្តិទាំងនោះនិយាយថាពួកគេធ្លាប់ជួបប្រទះ ឬដឹងលឺពីបញ្ហាពុករលួយនេះ ។ ក្រៅពីនេះ ការសិក្សាស្ទង់មតិឆ្នាំ ២០១៤ របស់អង្គការពលកម្មអន្តរជាតិ (ILO) បានបង្ហាញឱ្យឃើញថានៅពេលជួបប្រទះការអនុវត្តពុករលួយ ឬមិនត្រឹមត្រូវតាមសីលធម៌ ក្រុមហ៊ុនភាគច្រើន(៣៣%)នៅប្រទេសកម្ពុជាមិនចាត់វិធានការដោះស្រាយឡើយ មានតែ ១៩% ប៉ុណ្ណោះដែលបានបង្កើតគោលនយោបាយ ឬក្រមសីលធម៌ច្បាស់លាស់ ដើម្បីកាត់បន្ថយការអនុវត្តពុករលួយ និងមិនត្រឹមត្រូវតាមសីលធម៌ ។ លើសពីនេះ ប្រទេសកម្ពុជានៅមិនទាន់មានស្តង់ដារគ្រប់ជ្រុងជ្រោយដែលក្រុមហ៊ុនអាចយកទៅប្រើប្រាស់បានសម្រាប់ប្រឆាំងការសូកប៉ាន់នៅឡើយទេ ។

ស្តង់ដារអន្តរជាតិអាចជួយបំពេញចន្លោះខ្វះខាតនេះបានដោយការបង្កើតជាក្របខ័ណ្ឌសម្រាប់ឱ្យក្រុមហ៊ុនរៀបចំគោលនយោបាយនាពេលអនាគតដើម្បីដោះស្រាយបញ្ហាពុករលួយ ។ ឯកសារនេះក៏មានគោលបំណងបង្កើនការយល់ដឹង និងការទាមទារឱ្យដាក់បញ្ចូលស្តង់ដារធុរកិច្ចអន្តរជាតិទៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនផងដែរ ។ គោលបំណងយូរអង្វែង នៃការស្រាវជ្រាវនេះគឺបង្កើតនូវវប្បធម៌លើកស្ទួយសុចរិតភាព និងសីលធម៌ក្នុងវិស័យធុរកិច្ចនៅក្នុងប្រទេសកម្ពុជា ។

## កម្មវិធីសុចរិតភាពធុរកិច្ច (BIP) របស់អង្គការតម្លាភាពកម្ពុជា

អង្គការតម្លាភាពកម្ពុជាជាតំណាងប្រចាំប្រទេសរបស់អង្គការតម្លាភាពអន្តរជាតិដែលជាអង្គការសង្គមស៊ីវិលសកលលោកដឹកនាំការប្រឆាំងអំពើពុករលួយ ។ កម្មវិធីសុចរិតភាពធុរកិច្ចរបស់អង្គការតម្លាភាពកម្ពុជាបានចាប់ដំណើរការនៅខែមករា ឆ្នាំ ២០១៤ ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមអន្តរជាតិរបស់អង្គការតម្លាភាពអន្តរជាតិ ដើម្បីកាត់បន្ថយអំពើពុករលួយ តាមរយៈការលើកស្ទួយតម្លាភាព គណនេយ្យភាព និងសុចរិតភាពនៅក្នុងការអនុវត្តធុរកិច្ច ។ កម្មវិធីនេះធ្វើការជាមួយក្រុមហ៊ុនអាជីវកម្មតាមរយៈការផ្តល់សេវានិងការបណ្តុះបណ្តាលផ្សេងៗ ដើម្បីជួយក្រុមហ៊ុនឱ្យចៀសផុតពីហានិភ័យនៃអំពើពុករលួយ ។ សេវាផ្តល់ជូនរួមមានការជួយក្រុមហ៊ុនអនុវត្តប្រព័ន្ធសុចរិតភាពសាជីវកម្ម(CIS) ដោយផ្នែក ឬទាំងមូល វគ្គបណ្តុះបណ្តាលមូលដ្ឋានច្បាប់ប្រឆាំងអំពើពុករលួយ តម្លៃសេវាសាធារណៈ និងមូលដ្ឋានគ្រឹះនៃនីតិវិធីច្បាប់បញ្ញត្តិ ។ កម្មវិធីសុចរិតភាពធុរកិច្ចក៏មានផ្តល់ការត្រួតពិនិត្យ ការវាយតម្លៃហានិភ័យ និងការបណ្តុះបណ្តាលបច្ចេកទេសអំពីឧបករណ៍វាយតម្លៃដោយខ្លួនឯងផ្តោតលើនីតិវិធីនិងគោលនយោបាយប្រតិបត្តិតាមបច្ចុប្បន្នរបស់ក្រុមហ៊ុនដើម្បីបង្កើនប្រសិទ្ធភាពឱ្យដល់កម្រិតអតិបរមា ។ កម្មវិធីសុចរិតភាពធុរកិច្ចកំពុងតែប្រមូលផ្តុំនិងស្រាវជ្រាវព័ត៌មានទាក់ទងនឹងស្តង់ដារអន្តរជាតិដើម្បីណែនាំទៅដល់វិស័យធុរកិច្ចនៅក្នុងប្រទេសកម្ពុជា ។

## អត្ថប្រយោជន៍នៃស្តង់ដារអន្តរជាតិ

### ទាក់ទងជាមួយនឹងអ្នកទិញនិងវិនិយោគទុន

វិស័យឧស្សាហកម្មសំខាន់ៗនៅប្រទេសកម្ពុជា ដូចជា វិស័យកសិកម្ម និងកម្មន្តសាលកម្មធុនស្រាលគឺជាប្រភេទវិស័យដែលជំរុញដោយអ្នកទិញ ជាជាងដោយផលិតករ ។ ឧស្សាហកម្មដែលមានខ្សែចង្វាក់តម្លៃជំរុញដោយអ្នកទិញមានរបាំងចូលទីផ្សារទាប ដែលជាហេតុនាំឱ្យមានការប្រកួតប្រជែងច្រើនជាងឧស្សាហកម្មដែលជំរុញដោយផលិតករ ។ ដោយសារមានការប្រកួតប្រជែងច្រើនបែបនេះ ផលិតករត្រូវធ្វើឱ្យផលិតផលរបស់ពួកគេខុសពីគេតាមរយៈការរចនាផលិតផល ឬការធ្វើទីផ្សារដើម្បីរក្សា ឬបង្កើនកិច្ចការជំនួញជាមួយអ្នកទិញ ។ ដូចនេះភាពជោគជ័យរបស់ក្រុមហ៊ុននៅក្នុងឧស្សាហកម្មដែលជំរុញដោយអ្នកទិញគឺពឹងផ្អែកទាំងស្រុងទៅលើការគាំទ្រពីអ្នកទិញ ។ គួរបញ្ជាក់ផងដែរថាពាណិជ្ជករ និងអ្នកទិញ គឺជាតួអង្គពហុជាតិដែលនាំយកផលិតផលរបស់ផលិតករទៅលក់នៅទីផ្សារអន្តរជាតិ ។

> ទ្រព្យវិនិយោគមាននិរន្តរភាពនៅក្នុងតំបន់អាស៊ីបានកើនឡើងពី ៤០ពាន់លាន ទៅ ៥៣ពាន់លានដុល្លារ ពីចន្លោះឆ្នាំ២០១២ ទៅ២០១៤ដែលមានកំណើនសរុបដល់ទៅ ៣២ភាគរយ ។

ការប្រើប្រាស់ស្តង់ដារអន្តរជាតិប្រតិបត្តិតាមនិងប្រឆាំងការសូកប៉ាន់ នឹងជួយឱ្យផលិតករមានសមត្ថភាពប្រកួតប្រជែងកាន់តែខ្លាំងជាងផលិតករដែលមិនប្រើប្រាស់ស្តង់ដារទាំងនេះ ។ ក្រុមហ៊ុនអន្តរជាតិនាពេលបច្ចុប្បន្នកំពុងតែប្រកាន់ជំហរកាន់តែរឹងមាំចំពោះការអនុវត្តធុរកិច្ចស្អាតស្អំ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗដូចជាអតិថិជន និងអ្នកពាក់ព័ន្ធផ្សេងទៀត ។ ដូចនេះ ក្រុមហ៊ុនទាំងនោះអាចបង្កើតភាពជាដៃគូជាមួយផលិតករដែលមានទំនួលខុសត្រូវចំពោះសង្គមខ្ពស់ ។

យោងតាមរបាយការណ៍ត្រួតពិនិត្យឡើងវិញពីការ



© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

វិនិយោគមាននិរន្តរភាពជាសកលឆ្នាំ២០១៤ បានឱ្យដឹងថា ទីផ្សារវិនិយោគមាននិរន្តរភាពជាសកលបានកើនឡើងពី ២១,៥% (ឆ្នាំ២០១២) ដល់ ៣០,២% (ឆ្នាំ២០១៤) នៃទ្រព្យសកម្មដែលស្ថិតក្រោមការគ្រប់គ្រងដោយវិជ្ជាជីវៈ ។ បើយោងតាមរបាយការណ៍នេះ ទ្រព្យវិនិយោគមាននិរន្តរភាពនៅតំបន់អាស៊ីកើនឡើងពី ៤០ពាន់លានដុល្លារក្នុងឆ្នាំ២០១២ ដល់៥៣ពាន់លានដុល្លារក្នុងឆ្នាំ២០១៤ ដែលមានកំណើនសរុបដល់ទៅ ៣២% ។ ស្ថិតិទាំងនេះបង្ហាញពីនិន្នាការនៃកំណើនអ្នកវិនិយោគទុនលើជំនួញដែលពួកគេយល់ឃើញថាកាន់តែមាននិរន្តរភាព ។

ការដាក់បញ្ចូលស្តង់ដារធុរកិច្ចអន្តរជាតិទៅក្នុងគោលនយោបាយក្រុមហ៊ុនធ្វើឱ្យអ្នកទិញ ក៏ដូចជាអ្នកវិនិយោគមានទំនុកចិត្តលើវិជ្ជាជីវៈនិងសុចរិតភាពរបស់ផលិតករហើយក៏ធានានូវនិរន្តរភាពធុរកិច្ចផងដែរ ។ ក្រុមហ៊ុនអាចទទួលបានអត្ថប្រយោជន៍ជាច្រើនពីការមានកេរ្តិ៍ឈ្មោះល្អប្រសើរនៅក្នុងប្រទេសកម្ពុជាដែលកំពុងតែក្លាយជាប្រទេសគោលដៅវិនិយោគដ៏ទាក់ទាញ ។ ក្នុងឆ្នាំ២០១៤ ប្រទេសកម្ពុជាត្រូវបានគេសង្កេតឃើញថាជាប្រទេសមួយក្នុងចំណោម "ប្រទេសដែលមានការរីកលូតលាស់ បំផុតក្នុងការចូលរួមចំណែកដល់ខ្សែចង្វាក់តម្លៃផលិតកម្មជាសកល"[1] ។ ការសង្កេតនេះធ្វើឡើងបន្ទាប់ពីមានការវិនិយោគយ៉ាងសន្ធឹកសន្ធាប់ពីប្រទេសជប៉ុនលើវិស័យកម្មន្តសាលកម្មនៅក្នុងប្រទេសកម្ពុជាដែលនេះជាកត្តាជំរុញឱ្យអ្នកវិនិយោគទុនដទៃទៀតធ្វើការកត់សម្គាល់ ។

លើសពីនេះ ស្តង់ដារអន្តរជាតិត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយជាងស្តង់ដារក្នុងស្រុកពីសំណាក់អ្នកទិញអន្តរជាតិ ។ ក្រុមហ៊ុនដែលធ្លាប់មានជាប់ពាក់ព័ន្ធនឹងអំពើពុករលួយនិងការសូកប៉ាន់ ហើយមានកេរ្តិ៍ឈ្មោះមិនសូវល្អក៏អាចប្រើប្រាស់ស្តង់ដារអន្តរជាតិនេះដើម្បីទទួលបានជាថ្មីនូវទំនុកចិត្តពីភាគីពាក់ព័ន្ធ ។ សម្រាប់ភាគីពាក់ព័ន្ធ ការដាក់បញ្ចូលស្តង់ដារអន្តរជាតិនេះគឺជាការបញ្ជាក់ពីឆន្ទៈ និងជំហរថ្មីរបស់ក្រុមហ៊ុនក្នុងការធ្វើធុរកិច្ចស្អាតស្អំ ។

នេះជាការធានាមួយដែលនឹងជួយពង្រឹងទំនាក់ទំនងរវាងក្រុមហ៊ុន អ្នកទិញ និងអ្នកវិនិយោគឱ្យកាន់តែរឹងមាំមានការជឿទុកចិត្តរឹតតែខ្លាំង និងនិរន្តរភាពកាន់តែយូរអង្វែង។ សក្តានុពលនៃកំណើនវិនិយោគទុន និងទំនាក់ទំនងរវាងក្រុមហ៊ុនអន្តរជាតិនិងក្រុមហ៊ុនក្នុងស្រុកនេះនឹងផ្តល់នូវអត្ថប្រយោជន៍ដល់ក្រុមហ៊ុនកម្ពុជាដែលកំពុងតែពិចារណាចូលទីផ្សារក្នុងតំបន់ ឬសកល ។ បើសិនជាប្រទេសមួយមានកេរ្តិ៍ឈ្មោះមិនសូវល្អផ្នែកពលកម្ម និងសិទ្ធិមនុស្ស ការរួមបញ្ចូលស្តង់ដារទាំងនេះទៅក្នុងរចនាសម្ព័ន្ធក្រុមហ៊ុននឹងផ្តល់តម្លៃបន្ថែមទៅលើអាជីវកម្មរបស់ខ្លួនបើសិនជាក្រុមហ៊ុននោះមានបំណងធ្វើអាជីវកម្មនាំមុខគេនៅក្នុងទីផ្សារក្នុងតំបន់ ឬអន្តរជាតិ ។

## ទាក់ទងជាមួយនឹងក្រុមហ៊ុនមេ

ការដាក់បញ្ចូលស្តង់ដារប្រឆាំងការសូកប៉ាន់នឹងផ្តល់នូវរបាំងការពារខ្លួនដ៏រឹងមាំមួយសម្រាប់ក្រុមហ៊ុននៅពេលដែលមានការចោទប្រកាន់លើក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬសមាជិករបស់ខ្លួនពីបទល្មើសទាក់ទងនឹងការសូកប៉ាន់ ឬការប្រព្រឹត្តពុករលួយ ។ ក្រុមហ៊ុនអាចការពារខ្លួនបាននៅចំពោះមុខច្បាប់ និងអាចកាត់បន្ថយភាពងាយនឹងទទួលការចោទប្រកាន់ បើសិនជាក្រុមហ៊ុនអាចអះអាងបង្ហាញថានៅក្នុងរចនាសម្ព័ន្ធក្រុមហ៊ុនទាំងមូលរបស់ខ្លួនមានប្រព័ន្ធគ្រប់គ្រងការប្រឆាំងការសូកប៉ាន់ (ABMS) ដែលបញ្ជាក់ដោយស្តង់ដារអន្តរជាតិ ។

[1] "ការធ្លាក់ចុះនៃខ្សែចង្វាក់តម្លៃ: អង្គការពាណិជ្ជកម្មពិភពលោក" http://www.phnompenhpost.com/business/value-chain-decline-wto.


© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

ចំណុចនេះមានបកស្រាយលម្អិតនៅក្នុងផ្នែក **BS 10500** នៃឯកសារនេះ ។

## ទាក់ទងជាមួយនឹងបុគ្គលិកផ្ទៃក្នុង

ការដាក់បញ្ចូលស្តង់ដារប្រឆាំងការសូកប៉ាន់អាចជួយពង្រឹងរចនាសម្ព័ន្ធប្រឆាំងការសូកប៉ាន់ ឬប្រតិបត្តិតាមដែលក្រុមហ៊ុនមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីបង្កើតនីតិវិធីស្តង់ដារសម្រាប់អនុវត្តនៅពេលជួបប្រទះនឹងការសូកប៉ាន់ ។ វត្តមានរបស់នីតិវិធីស្តង់ដារសម្រាប់អនុវត្តនឹងផ្តល់នូវភាពអាចព្យាករណ៍ដឹងមុនបាន ព្រមទាំងជួយបុគ្គលិកឱ្យយល់ដឹងពីបែបបទដែលត្រូវអនុវត្តនៅពេលពួកគេស្ថិតក្នុងស្ថានភាពទាក់ទិននឹងការសូកប៉ាន់ ដូចនេះជួយឱ្យបុគ្គលិកធ្វើការសម្រេចចិត្តបានល្អប្រសើរ និងការពារសកម្មភាពអាជីវកម្មមិនឱ្យមានការរាំស្ទះ ។ ក្រៅពីនេះប្រព័ន្ធទប់ស្កាត់អំពើពុករលួយនឹងជួយរារាំងបុគ្គលិកក្នុងការផ្តល់ ឬទទួលសំណូកមិនឱ្យកើតឡើងតាំងពីដំបូង ។

មានស្តង់ដារផ្សេងៗជាច្រើនដែលក្រុមហ៊ុនអាចអនុវត្តតាមដើម្បីទាញយកនូវអត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ។

# ប្រភេទស្តង់ដារ

## គ្លូបលកំផែករបស់អង្គការសហប្រជាជាតិ (UNGC)

គ្លូបលកំផែករបស់អង្គការសហប្រជាជាតិគឺជាកិច្ចផ្តួចផ្តើមនិរន្តរភាពរបស់អង្គការសហប្រជាជាតិ ដែលមានគោលបំណងកសាងភាពជាដៃគូជាមួយវិស័យធុរកិច្ច និងសហគមន៍ដើម្បីអនុវត្តគោលការណ៍ទាំងដប់របស់គ្លូបលកំផែកនេះ ។ គោលការណ៍ទាំងនោះផ្តោតលើសិទ្ធិមនុស្ស បរិស្ថាន ពលកម្ម និងជាពិសេសការប្រឆាំងអំពើពុករលួយ ដែលរួមមាន[2]៖

- សហគ្រាសពាណិជ្ជកម្មត្រូវគាំទ្រ គោរព និងការពារសិទ្ធិមនុស្សដូចមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- ធានាថាមិនចូលរួមពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស
- សហគ្រាសពាណិជ្ជកម្មត្រូវគោរពនូវសេរីភាពក្នុងការបង្កើតសមាគមនិងសិទ្ធិនៃការចរចាជាសមូហភាព
- លុបបំបាត់រាល់ទម្រង់នៃពលកម្មដោយបង្ខំ
- លុបបំបាត់ពលកម្មកុមារ និង
- លុបបំបាត់ការរើសអើងនៅក្នុងការជ្រើសរើសបុគ្គលិក និងនៅក្នុងការងារ
- សហគ្រាសពាណិជ្ជកម្មត្រូវគាំទ្រវិធីសាស្ត្រដោះស្រាយដោយប្រុងប្រយ័ត្នចំពោះបញ្ហាប្រឈមផ្នែកបរិស្ថាន
- អនុវត្តកិច្ចផ្តួចផ្តើមលើកស្ទួយទំនួលខុសត្រូវកាន់តែខ្ពស់ចំពោះបរិស្ថាន និង
- ជំរុញការអភិវឌ្ឍនិងផ្សព្វផ្សាយបច្ចេកវិទ្យាដែលមិនប៉ះពាល់ដល់បរិស្ថាន
- **សហគ្រាសពាណិជ្ជកម្មត្រូវប្រឆាំងអំពើពុករលួយគ្រប់ទម្រង់រាប់បញ្ចូលទាំងការជំរិតទារ និងការសូកប៉ាន់ ។**

គោលការណ៍ទាំងអស់នេះផ្តល់នូវក្របខណ្ឌគោលនយោបាយសាធារណៈសម្រាប់ក្រុមហ៊ុន រៀបចំបង្កើត អនុវត្ត និងដាក់បញ្ចេញគោលនយោបាយពេញលេញស្តីពីទំនួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម

[2] គោលការណ៍ទាំងដប់នៃកតិកាសញ្ញាជាសកលរបស់អង្គការសហប្រជាជាតិ https://www.unglobalcompact.org/what-is-gc/mission/principles


© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

ព្រមទាំងគោលនយោបាយប្រឆាំងអំពើពុករលួយផង ដែរ ។ សហគ្រាសពាណិជ្ជកម្មដែលមានចំណាប់អារម្មណ៍លើការអនុវត្តក្របខ័ណ្ឌនេះអាចចុះឈ្មោះដើម្បីក្លាយជាហត្ថលេខីរបស់គ្លូបលកំផែកនេះ ។ ហត្ថលេខីទាំងអស់អាចអនុវត្តក្របខ័ណ្ឌនេះនៅក្នុងប្រទេសនិងថ្នាក់អន្តរជាតិបាន ។ ហត្ថលេខីអាចបង្កើតបណ្តាញគ្លូបលកំផែករបស់អង្គការសហប្រជាជាតិនៅក្នុងស្រុក ឬក៏ចូលរួមក្នុងកិច្ចផ្តួចផ្តើមរបស់គ្លូបលកំផែកនេះនៅថ្នាក់អន្តរជាតិ ។ ជាទូទៅ បណ្តាញក្នុងស្រុកគ្រប់គ្រងដោយអ្នកតំណាងដែលតែងតាំងដោយគណៈកម្មាធិការគ្រប់គ្រងដែលមានតំណាងមកពីសាជីវកម្មពហុជាតិ ក្រុមហ៊ុនដឹកនាំគ្លូបលកំផែកសហគ្រាសធុនតូចនិងមធ្យម និងសមាជិកសង្គមស៊ីវិល ។ ក្រុមហ៊ុនដឹកនាំគ្លូបលកំផែកទាំងនោះមានកម្មវិធីទំនួលខុសត្រូវចំពោះសង្គមកាន់តែជឿនលឿនធ្វើការកាន់តែសកម្មជាមួយភ្នាក់ងារ UN ពាក់ព័ន្ធបន្តបង្កើតកម្មវិធីកាន់តែមានប្រសិទ្ធភាពដើម្បីចែករំលែកព័ត៌មានជាមួយនឹងសមាជិកបណ្តាញ UNGC ក្នុងស្រុកដទៃផ្សេងទៀត និងចូលរួមកិច្ចប្រជុំឯកជនជាន់ខ្ពស់កាន់តែច្រើន ។

បច្ចុប្បន្ននេះ គ្លូបលកំផែកនេះមានក្រុមហ៊ុនចូលរួមចំនួនលើស ១០,០០០ ដែលមកពីប្រទេសជាង ១៤៥ ។ សកម្មភាពដែលហត្ថលេខីអាចចូលរួមមានដូចជាកិច្ចសន្ទនាអំពីគោលនយោបាយ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗទាក់ទងនឹងគោលការណ៍របស់គ្លូបលកំផែក ក៏ដូចជាការអនុវត្តទីផ្សារនិងគំរូធុរកិច្ចមាននិរន្តរភាព ។ សកម្មភាពផ្សេងទៀតមានដូចជាចូលរួមផ្សព្វផ្សាយផលិតផល និងសេវាប្រមូលព័ត៌មានពីករណីសិក្សាអំពីការអភិវឌ្ឍទីផ្សារសម្រាប់ទាំងអស់គ្នារបស់ក្រុមហ៊ុន  យុទ្ធសាស្ត្រលើកកម្ពស់ការងារទាក់ទងនឹងទំនួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម និងធនធានក៏ដូចជាឧបករណ៍សម្រាប់ការគ្រប់គ្រងនានា ។

## ការចុះឈ្មោះចូលរួមក្នុងគ្លូបលកំផែករបស់អង្គការសហប្រជាជាតិ

ដើម្បីចុះឈ្មោះចូលរួមក្នុងគ្លូបលកំផែកក្រុមហ៊ុនតម្រូវឱ្យមានលិខិតប្តេជ្ញាចិត្ត ដែលចុះហត្ថលេខាដោយថ្នាក់ដឹកនាំធំជាងគេបំផុតនៅក្នុងក្រុមហ៊ុន (ដូចជានាយកប្រតិបត្តិ) ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះគ្លូបលកំផែក និងគោលការណ៍ទាំងដប់របស់គ្លូបលកំផែក ។ ក្រុមហ៊ុនត្រូវបំពេញទម្រង់បែបបទតាមអនឡាញ និងភ្ជាប់ជាមួយនូវច្បាប់ចម្លងអេឡិចត្រូនិចនៃលិខិតប្តេជ្ញាចិត្ត ។

ក្រុមហ៊ុននឹងត្រូវបំពេញកាតព្វកិច្ចជាច្រើនផ្សេងទៀតដូចជាផ្តល់វិភាគទានហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីទ្រទ្រង់គ្លូបលកំផែក និងជាពិសេសផ្តល់របាយការណ៍ប្រចាំឆ្នាំអំពីដំណើរការនៃការអនុវត្តគោលការណ៍ទាំងដប់របស់គ្លូបលកំផែកអំឡុងពេលមួយឆ្នាំកន្លងមក ។ គួរកត់សម្គាល់ថារបាយការណ៍នេះអាចជាឯកសារមួយដាច់ដោយឡែកតែឯង ឬជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

សម្រាប់ព័ត៌មានបន្ថែម អាចស្វែងរកបាននៅ http://www.unglobalcompact.org.

## BS 10500

BS 10500 គឺជាប្រព័ន្ធគ្រប់គ្រងការប្រឆាំងការសូកប៉ាន់ដែលបង្កើតឡើងដោយស្ថាប័នស្តង់ដារអង់គ្លេស។ ស្តង់ដារនេះមានសម្រាប់ក្រុមហ៊ុនគ្រប់ទំហំដោយសារវាមានលក្ខណៈអាចផ្លាស់ប្តូរបានទៅតាមតម្រូវការ


© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

ហើយប្រព័ន្ធនេះក៏អាចរកបាននៅទូទាំងពិភពលោក សម្រាប់ឱ្យក្រុមហ៊ុនប្រើប្រាស់ផងដែរ ។

លក្ខណៈពិសេសប្លែកពីគេរបស់ប្រព័ន្ធ BS 10500 នេះគឺថាប្រព័ន្ធនេះយកច្បាប់ប្រឆាំងការសូកប៉ាន់របស់ចក្រភពអង់គ្លេសឆ្នាំ២០១០ ធ្វើជាមូលដ្ឋានដើម្បីសម្របខ្លួនតាមតម្រូវការផ្នែកផ្លូវច្បាប់របស់ចក្រភពអង់គ្លេស ។ ឧទាហរណ៍ មាត្រា២ ផ្នែកទី៧ នៃច្បាប់នេះបានចែងថានៅពេលក្រុមហ៊ុនទទួលការចោទប្រកាន់ពីបទសូកប៉ាន់ ក្រុមហ៊ុនត្រូវបង្ហាញថាខ្លួនមាន "នីតិវិធីគ្រប់គ្រាន់" ក្នុងការទប់ស្កាត់និយោជិតមិនឱ្យទទួលសំណូក ។ភស្តុតាងបង្ហាញនេះនឹងក្លាយជា "របាំងការពារ" ក្រុមហ៊ុននៅក្នុងដំណើរការកាត់ក្តីជាពិសេសទោះបីជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនមេ និយោជិត ឬអ្នកពាក់ព័ន្ធផ្សេងទៀតត្រូវបានគេឃើញថាបានប្រព្រឹត្តអំពើពុករលួយពិតមែន ។ ដូចនេះប្រព័ន្ធ BS 10500 នេះមានការធានានូវលក្ខណៈ "គ្រប់គ្រាន់" ស្របទៅតាមក្របខ័ណ្ឌច្បាប់ប្រឆាំងការសូកប៉ាន់ ។ ក្រុមហ៊ុនដែលស្ថិតក្រោមច្បាប់ប្រឆាំងការសូកប៉ាន់របស់ចក្រភពអង់គ្លេសនេះអាចយកស្តង់ដារBS 10500នេះធ្វើជាវិធានការបង្ការទុកមុនសម្រាប់នៅពេលមានករណីជាប់ទាក់ទិននឹងការសូកប៉ាន់ ។ ក្រុមហ៊ុនដែលមានទំនួលខុសត្រូវចំពោះច្បាប់នេះរួមមានក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេសរបស់ក្រុមហ៊ុនចក្រភពអង់គ្លេសដែលអាចធ្វើឱ្យក្រុមហ៊ុនមេទទួលខុសត្រូវចំពោះមុខច្បាប់បើសិនជាក្រុមហ៊ុនបុត្រសម្ព័ន្ធនោះប្រព្រឹត្តការសូកប៉ាន់ ។ ក្រៅពីនេះក្រុមហ៊ុនបរទេសដែលចង់ធ្វើធុរកិច្ចនៅចក្រភពអង់គ្លេសក៏អាចទទួលការចោទប្រកាន់យោងតាមច្បាប់នេះផងដែរ ។

ប្រព័ន្ធគ្រប់គ្រងប្រឆាំងការសូកប៉ាន់ BS 10500 ផ្តល់យ៉ាងទូលំទូលាយនូវនីតិវិធីប្រឆាំងអំពើពុករលួយ និងការសូកប៉ាន់ក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ទាំងមូលរបស់ក្រុមហ៊ុន ក៏ដូចជាទំនាក់ទំនងជាមួយដៃគូអាជីវកម្ម និងអតិថិជន ។ នីតិវិធីទាំងនេះគ្របដណ្តប់លើចំណុចសំខាន់ៗដូចជា នីតិវិធីជ្រើសរើសបុគ្គលិក គោលនយោបាយស្តីពីអំណោយនិងវិភាគទាន ការបង់ប្រាក់សម្រួលការងារ ការត្រួតពិនិត្យលទ្ធកម្ម ការរៀបចំសម្រាប់ការរាយកាណ៍សម្ងាត់ និងការត្រួតពិនិត្យឡើងវិញអំពីការគ្រប់គ្រងថ្នាក់លើ ។ នៅចុងបញ្ចប់ក្រុមហ៊ុននឹងអាចទទួលបានវិញ្ញាបនបត្រពីភាគីទីបីឯករាជ្យបញ្ជាក់ពីប្រព័ន្ធBS 10500របស់ក្រុមហ៊ុន ។

ដំណើរការនៃការធ្វើវិញ្ញាបនកម្មប្រព័ន្ធ BS 10500 មានដូចតទៅ៖

## ១. ដាក់ពាក្យស្នើសុំ

ដាក់ពាក្យស្នើសុំវិញ្ញាបនបត្រតាមគេហទំព័ររបស់ប្រព័ន្ធ BS 10500 (ដូចមានបង្ហាញនៅខាងក្រោម) ដោយស្នើសុំសម្រង់តម្លៃ ឬព័ត៌មានលម្អិត ។ ប្រធានផ្នែកអតិថិជននឹងធ្វើការណែនាំដល់ក្រុមហ៊ុនពីជំហានដែលត្រូវធ្វើបន្ទាប់ ។

## ២. វាយតម្លៃ

ត្រួតពិនិត្យពីភាពត្រៀមខ្លួនរួចរាល់របស់ក្រុមហ៊ុនដើម្បីមើលថាតើនីតិវិធីចំបាច់របស់ប្រព័ន្ធ BS 10500 មានហើយឬនៅ ។ បើសិនជាមាន ការវាយតម្លៃផ្លូវការពីនីតិវិធីបច្ចុប្បន្នរបស់ក្រុមហ៊ុននឹងចាប់ផ្តើមដើម្បីបញ្ជាក់ថានីតិវិធីទាំងនោះត្រូវបានអនុវត្ត និងដំណើរការប្រកបដោយប្រសិទ្ធភាព ដែលនេះជាតម្រូវការចាំបាច់មុននឹងទទួលបានវិញ្ញាបនបត្រ ។ បើសិនជានៅមិនទាន់មាននីតិវិធីគ្រប់គ្រាន់ទេនោះ ក្រុមហ៊ុនBSI អាចជួយក្រុមហ៊ុនក្នុងការអនុវត្តកញ្ចប់សេវាដែលរៀបចំទៅតាមតម្រូវការរបស់ក្រុមហ៊ុន ។


© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

## ៣. វាយតម្លៃទទួលស្គាល់

បន្ទាប់ពីឆ្លងផុតការវាយតម្លៃរួច ក្រុមហ៊ុននឹងទទួលបានវិញ្ញាបនបត្រប្រព័ន្ធBS 10500 ដែលមានសុពលភាពរយៈពេល ៣ឆ្នាំ ។

## ៤. វាយតម្លៃលើការអនុវត្ត

ប្រធានផ្នែកអតិថិជននឹងចុះពិនិត្យក្រុមហ៊ុនជាប្រចាំដើម្បីពង្រឹងប្រព័ន្ធឱ្យប្រសើរឡើង និងធានាថាប្រព័ន្ធនេះនៅតែអនុលោមតាមស្តង់ដារ BS 10500 ។

ក្រុមហ៊ុនBSIគ្រុបមានការិយាល័យក្នុងតំបន់ជាច្រើនសម្រាប់ឱ្យក្រុមហ៊ុននៅក្នុងទីបផ្សេងៗស្វែងរកព័ត៌មានទាក់ទងពីសេវាកម្មរបស់ពួកគេ ។ ការិយាល័យក្នុងតំបន់ដែលនៅជិតប្រទេសកម្ពុជាជាងគេនោះគឺស្ថិតនៅប្រទេសថៃ ។ ក្រុមហ៊ុនក៏អាចពិភាក្សាជាមួយសាជីវកម្មផ្តល់សេវាអធិការកិច្ចនិងសវនកម្មរបស់ប្រទេសស្វីស SGS SA ពីប្រព័ន្ធBS 10500 នេះផងដែរ ។ SGS ក៏មានការិយាល័យនៅក្នុងទីក្រុងភ្នំពេញប្រទេសកម្ពុជាដែរ ។

សម្រាប់ព័ត៌មានបន្ថែម អាចស្វែងរកបាននៅគេហទំព័រតាមរយៈ http://www.bsigroup.com/en-GB/BS-10500-Anti-Bribery/.

## ច្បាប់ស្តីពីការអនុវត្តពុករលួយក្រៅប្រទេស ឆ្នាំ ១៩៧៧ (FCPA)

FCPA គឺជាច្បាប់ដែលមានយុត្តាធិការឆ្លងដែនដីដ៏ល្បីមួយដែលបានអនុម័តនៅសហរដ្ឋអាមេរិកសម្រាប់ដាក់ទោសការសូកប៉ាន់ក្នុងក្រុមហ៊ុនដែលធ្វើអាជីវកម្មជាមួយឬនៅក្នុងសហរដ្ឋអាមេរិក ។ ច្បាប់នេះមានយុត្តាធិការឆ្លងដែនដី ហើយបុគ្គល និងនីតិបុគ្គលដែលស្ថិតក្រោមច្បាប់នេះរួមមាន៖

- "គ្រឹះស្ថានសាជីវកម្មក្នុងស្រុក"៖ ក្រុមហ៊ុន/អង្គភាពសាជីវកម្មរបស់សហរដ្ឋអាមេរិក រាប់បញ្ចូលទាំងក្រុមហ៊ុនដែលធ្វើអាជីវកម្មនៅបរទេសតាមរយៈបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនវិនិយោគរួមក្រៅប្រទេស
- "អ្នកចេញមូលបត្រ"៖ ក្រុមហ៊ុនសាធារណៈបរទេសនិងសហរដ្ឋអាមេរិកដែលធ្វើពាណិជ្ជកម្មមូលបត្រនៅក្នុងសហរដ្ឋអាមេរិក
- បុគ្គល ឬក្រុមហ៊ុនអាជីវកម្មបរទេសណាមួយដែលធ្វើសកម្មភាពនៅក្នុងដែនដីសហរដ្ឋអាមេរិក ។

ច្បាប់នេះមានចង្កោមបទប្បញ្ញត្តិចំនួនពីរចែងពីការប្រឆាំងការសូកប៉ាន់ និងគណនេយ្យ ។ បទប្បញ្ញត្តិស្តីពីការប្រឆាំងការសូកប៉ាន់រួមមានការហាមមិនឱ្យបង់ប្រាក់ដល់មន្ត្រីបរទេសដើម្បីទទួលបាន ឬរក្សាជំនួញ។ បទប្បញ្ញត្តិអំពីគណនេយ្យតម្រូវឱ្យក្រុមហ៊ុនចេញមូលបត្រកត់ត្រានិងរក្សាសៀវភៅនិងបញ្ជីឱ្យបានត្រឹមត្រូវ និងមានប្រព័ន្ធត្រួតពិនិត្យគណនេយ្យផ្ទៃក្នុងគ្រប់គ្រាន់ ។ បទប្បញ្ញត្តិទាំងនេះមិនអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការក្លែងបន្លំសៀវភៅ ឬបញ្ជីឡើយ ។ ផ្ទុយពីច្បាប់ប្រឆាំងការសូកប៉ាន់របស់ចក្រភពអង់គ្លេស ច្បាប់នេះមិនមានចែងពីជំនួញពុករលួយរវាងភាគីឯកជននោះឡើយ មានតែជំនួញរវាងភាគីឯកជន និងគ្រឹះស្ថានជំនួញរបស់រដ្ឋតែប៉ុណ្ណោះ ។

ទោះបីជាយ៉ាងនេះក្តីគួរកត់សម្គាល់ថាអំពើពុករលួយរវាងបុគ្គលឯកជន "អាចចាប់បាន" ដោយប្រើច្បាប់ផ្សេងទៀតរបស់សហរដ្ឋអាមេរិក ។[3]

[3] "ភាពខុសគ្នារវាងច្បាប់ប្រឆាំងការសូកប៉ាន់របស់ចក្រភពអង់គ្លេស និងច្បាប់ស្តីពីការអនុវត្តពុករលួយក្រៅប្រទេសរបស់សហរដ្ឋអាមេរិក" http://www.nortonrosefulbright.com/knowledge/publications/52195/differences-between-the-uk-bribery-act-and-the-us-foreign-corrupt-practices-act



© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

ទោះបីជាច្បាប់ស្ដីពីការអនុវត្តពុករលួយក្រៅប្រទេសនេះមិនសម្របខ្លួនតាមស្តង់ដារណាមួយក្តី សៀវភៅធនធានណែនាំពីច្បាប់នេះដែលចេញផ្សាយជាផ្លូវការក្នុងឆ្នាំ២០១២ ក៏បានផ្ដល់ជាគោលគំនិតជាច្រើនពីលក្ខណៈសណ្ឋានសំខាន់ៗនៃកម្មវិធីប្រតិបត្តិតាមប្រកបដោយ"ប្រសិទ្ធភាព" ដែលអនុលោមតាមច្បាប់ស្ដីពីការអនុវត្តពុករលួយក្រៅប្រទេស ដើម្បីកាត់បន្ថយហានិភ័យការសូកប៉ាន់នៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ។ លក្ខណៈសណ្ឋានទាំងនេះគឺជាចំណុចដ៏សំខាន់សម្រាប់ក្រុមហ៊ុនដែលស្ថិតនៅក្រោមការស៊ើបអង្កេតរបស់គណៈកម្មការមូលបត្រ និងនាយកដ្ឋានយុត្តិធម៌ នៅពេលមានការចោទប្រកាន់ពីបទចំពានលើច្បាប់ស្ដីពីការអនុវត្តពុករលួយក្រៅប្រទេសនេះ ។ លក្ខណៈសម្គាល់ទាំងនេះជារឿយៗត្រួតគ្នាជាមួយនឹងកម្មវិធីស្តង់ដារអន្តរជាតិដូចបានរៀបរាប់ពីមុន និងបន្ទាប់ទៀតនេះនៅក្នុងផ្នែក ISO37001 ។ តួយ៉ាង សៀវភៅណែនាំនេះបានផ្ដល់អនុសាសន៍ថាកម្មវិធីប្រតិបត្តិតាមត្រូវមានសេចក្ដីប្ដេជ្ញាចិត្តច្បាស់លាស់មួយពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងការរៀបចំគោលនយោបាយច្បាស់លាស់សម្រាប់ប្រឆាំងនឹងអំពើពុករលួយ ។ តម្រូវការទាំងនេះក៏ជំរុញឱ្យមានដោយស្តង់ដារអន្តរជាតិផងដែរ នៅពេលដែលក្រុមហ៊ុនស្នើសុំវិញ្ញាបនបត្រ ។ លក្ខណៈសម្គាល់ផ្សេងទៀតមាន ការវាយតម្លៃហានិភ័យ ការបណ្ដុះបណ្ដាលបុគ្គលិក និងវិធានការវិន័យ ជាដើម ។

ច្បាប់នេះគឺជាកត្តាដ៏សំខាន់មួយដែលអាចកំណត់ឱ្យអ្នកវិនិយោគសហរដ្ឋអាមេរិកជ្រើសរើសប្រទេសកម្ពុជាជាគោលដៅវិនិយោគមួយដែលមានសក្ដានុពល ។ ភាពរឹតត្បិតនៃច្បាប់មួយនេះធ្វើឱ្យក្រុមហ៊ុនសហរដ្ឋអាមេរិកមានការប្រយ័ត្ន និងចៀសវាងការពាក់ព័ន្ធនឹងជំនួញពុករលួយ ។ ការសិក្សាស្ទង់មតិរបស់សភាពាណិជ្ជកម្មអាមេរិកឆ្នាំ២០១៥ បានឱ្យដឹងថា ៨២%នៃពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកនៅប្រទេសកម្ពុជាមិនពេញចិត្តចំពោះអំពើពុករលួយព្រោះវាអាចធ្វើឱ្យក្រុមហ៊ុនទាំងនោះប្រឈមនឹងហានិភ័យខ្ពស់[4] ។ ការអនុវត្តស្តង់ដារស្របតាមលក្ខខ័ណ្ឌរបស់សៀវភៅណែនាំពីច្បាប់ស្ដីពីការអនុវត្តពុករលួយនៅក្រៅប្រទេសនេះនឹងជួយកាត់បន្ថយហានិភ័យក្នុងការធ្វើវិនិយោគនៅត្រឹមកម្រិតអប្បបរមា និងលើកស្ទួយប្រទេសកម្ពុជាឱ្យក្លាយជាទីកន្លែងមានសក្ដានុពលទាក់ទាញជំនាញ និងធនធានពីសហរដ្ឋអាមេរិកមកព្រះរាជាណាចក្រកម្ពុជា ។

## ស្តង់ដារ ISO37001

ISO37001 គឺជាស្តង់ដារអន្តរជាតិដំបូងគេបង្អស់បង្កើតឡើងសម្រាប់អនុវត្តប្រព័ន្ធគ្រប់គ្រងការប្រឆាំងការសូកប៉ាន់[5] ។ ស្តង់ដារនេះអាចប្រើក្នុងស្ថាប័នគ្រប់ទំហំ និងប្រភេទក្នុងវិស័យនានាដូចជា វិស័យសាធារណៈ វិស័យឯកជន និងវិស័យដែលមិនរកប្រាក់កម្រៃ ជាដើម ។ ចំណុចសំខាន់ៗនៃស្តង់ដារនេះរួមមានការបង្កើតសេចក្ដីព្រាងគោលនយោបាយប្រឆាំងការសូកប៉ាន់ ការតែងតាំងបុគ្គលិកសម្រាប់ត្រួតពិនិត្យលើការប្រតិបត្តិតាមប្រឆាំងការសូកប៉ាន់ ការបណ្ដុះបណ្ដាលបុគ្គលិក ការវាយតម្លៃហានិភ័យនៃការសូកប៉ាន់  ការត្រួតពិនិត្យនិងធ្វើរបាយការណ៍

[4] "អ្នកវិនិយោគសហរដ្ឋអាមេរិកខកចិត្តចំពោះភាពមិនច្បាស់លាស់ និងអំពើពុករលួយ" http://www.phnompenhpost.com/post-weekend/us-investors-put-uncertainty-and-corruption.

[5] ឧបករណ៍ថ្មីសម្រាប់ប្រឆាំងការសូកប៉ាន់ក្នុងពាណិជ្ជកម្ម http://www.iso.org/iso/news.htm?refid=Ref1902



© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

ហិរញ្ញវត្ថុនិងពាណិជ្ជកម្ម និងនីតិវិធីស៊ើបអង្កេត ។ ស្តង់ដារ ISO37001 នេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយសេចក្តីព្រាងស្តង់ដារនេះបង្កើតឡើងដោយមានការចូលរួមពីអ្នកជំនាញមកពីប្រទេសចូលរួមបង្កើតចំនួន ២៨ ប្រទេសចូលរួមធ្វើការសង្កេតចំនួន ១៦ និងស្ថាប័នទំនាក់ទំនងចំនួន ៧ ។[6] ស្តង់ដារនេះពុំទាន់រៀបចំរួចរាល់នៅឡើយទេ ប៉ុន្តែគ្រោងនឹងបញ្ចប់និងបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១៦ ។

## ករណីសិក្សាក្នុងតំបន់

### ប្រទេសម៉ាឡេស៊ី

ប្រទេសម៉ាឡេស៊ីបានសម្ពោធបណ្តាញគ្លូបលកំផែកដែលជាបណ្តាញក្នុងស្រុករបស់ខ្លួននៅឆ្នាំ២០០៨ ។ បច្ចុប្បន្នប្រទេសម៉ាឡេស៊ីមានហត្ថលេខីជាសមាជិកបណ្តាញចំនួន ៥០ ដែលក្នុងនោះមានក្រុមហ៊ុនមកពីផ្នែកអេឡិចត្រូនិច និងឧបករណ៍អគ្គិសនី សូហ្វវែរ និងសេវាកម្មកុំព្យូទ័រ សេវាផ្តល់ការគាំទ្រ និងឧស្សាហកម្មទូទៅ ។ បណ្តាញនេះគឺជានីតិបុគ្គលឯករាជ្យ ដែលស្ថិតក្រោមច្បាប់ស្តីពីការចុះឈ្មោះសមាគមរបស់ប្រទេសម៉ាឡេស៊ី ។

## ក្រុមហ៊ុនហ្វ៊ូជី ហ្សេរ៉ក់ស៍ ប្រទេសម៉ាឡេស៊ី

ក្រុមហ៊ុន ហ្វ៊ូជី ហ្សេរ៉ក់ស៍គឺជាក្រុមហ៊ុនកែច្នៃឯកសារពហុជាតិអាមេរិក-ជប៉ុន ដែលមានក្រុមហ៊ុនបុត្រសម្ព័ន្ធនៅប្រទេសម៉ាឡេស៊ី ។ ក្រុមហ៊ុននេះ បានចូលជាបណ្តាញគ្លូបលកំផែកក្នុងស្រុក តាំងពីការចាប់កំណើតនៃបណ្តាញនេះនៅឆ្នាំ២០០៨ មកម្លេះ ហើយបច្ចុប្បន្ននេះគឺជាក្រុមហ៊ុនដឹកនាំគ្លូបលកំផែកតែមួយគត់នៅក្នុងបណ្តាញ ។ ក្រោយពីបានចូលរួមក្នុងគ្លូបលកំផែកមក ហ្វ៊ូជី ហ្សេរ៉ក់ស៍បានប្រើប្រាស់ឧបករណ៍ និងធនធានរបស់គ្លូបលកំផែកដើម្បីកែប្រែក្រមសីលធម៌ក្រុមហ៊ុនរបស់ខ្លួននៅក្នុងឆ្នាំ២០០៧ ឱ្យស្របតាមគោលការណ៍របស់គ្លូបលកំផែក ។ ក្រុមហ៊ុននេះនៅតែបន្តពិនិត្យមើលឡើងវិញ និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយសីលធម៌របស់ខ្លួនដើម្បីរក្សាភាពអនុលោមតាមស្តង់ដារអន្តរជាតិ ។ ហ្វ៊ូជី ហ្សេរ៉ក់ស៍បានណែនាំប្រាប់អំពីការកែប្រែក្រមសីលធម៌នេះទៅដល់បុគ្គលិករបស់ខ្លួនតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលអំពីការប្រតិបត្តិតាម អស់រយៈពេលមួយឆ្នាំដើម្បីឱ្យពួកគេយល់ច្បាស់ពីភាពចាំបាច់នៃការកាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវហានិភ័យពាក់ព័ន្ធនឹងការរំលោភបំពានច្បាប់ប្រឆាំងអំពើពុករលួយ ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះក៏បានផ្តល់ផលមកវិញដល់ក្រុមហ៊ុនផងដែរ ។ របាយការណ៍និរន្តរភាពឆ្នាំ២០១៤ របស់ក្រុមហ៊ុនបានបង្ហាញឱ្យឃើញថា រហូតមកដល់ពេលឥឡូវនេះ ពុំមានករណីពុករលួយត្រូវបានអះអាងថាកើតមាននៅក្នុងក្រុមហ៊ុនឡើយ ។

### ប្រទេសឥណ្ឌូនេស៊ី

ប្រទេសឥណ្ឌូនេស៊ីបានសម្ពោធបណ្តាញគ្លូបលកំផែកក្នុងស្រុករបស់ខ្លួន នៅខែមេសា ឆ្នាំ២០០៦ អំឡុងពេលវេទិកាពាណិជ្ជកម្មអាស៊ីប៉ាស៊ីហ្វិក ។ បច្ចុប្បន្នបណ្តាញនេះមានហត្ថលេខីចំនួន ១១៧ ដែលរួមមានសាជីវកម្មពហុជាតិ សាជីវកម្មជាតិ សហគ្រាសធុនតូច និងមធ្យម សាកលវិទ្យាល័យ និងអង្គការសង្គមស៊ីវិលជាច្រើន ។ សកម្មភាពរបស់បណ្តាញមានដូចជារៀបចំសន្និសីទបណ្តាញសម្រាប់

[6] ស្តង់ដារប្រព័ន្ធគ្រប់គ្រងការប្រឆាំងការសូកប៉ាន់ ISO37001 http://www.iso.org/iso/iso_37001_anti-bribery_management_systems_standard_brochure.pdf


© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

ឱ្យហត្ថលេខីទទួលបានអត្ថប្រយោជន៍ក្នុងកម្រិតអតិបរមាពីគ្លូបលកំផែកនេះ និងរៀបចំកិច្ចផ្តួចផ្តើមពីទំនួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គមជាមួយភ្នាក់ងារអង្គការសហប្រជាជាតិផ្សេងទៀតដូចជាយូនីស្វូ ជាដើម ។

## ក្រុមហ៊ុនអាស៊ី ផល&ផេបធី គ្រុប (APP)

ក្រុមហ៊ុនអាស៊ី ផល&ផេបធី គ្រុប គឺជាក្រុមហ៊ុនផលិតក្រដាសដែលជាកម្មសិទ្ធិរបស់រោងម៉ាស៊ីនក្រដាស PT Indah Kiat Pulp & Paper Tbk និងរោងម៉ាស៊ីនក្រដាស PT Pindo Deli Pulp & Papers ។ ក្រុមហ៊ុនទាំងពីរនេះជាសមាជិកបណ្តាញគ្លូបលកំផែកក្នុងស្រុករបស់ប្រទេសឥណ្ឌូនេស៊ី ។ ក្រុមហ៊ុនAPPបានចុះហត្ថលេខាជាមួយគ្លូបលកំផែកនៅឆ្នាំ២០០៨ ។ យោងតាមការរាយការណ៍អំពីកិច្ចបន្តការគាំទ្របណ្តាញ នៅក្នុងបាយការណ៍ឆ្នាំ២០១២របស់ក្រុមហ៊ុន គោលការណ៍របស់គ្លូបលកំផែកនៅតែបន្តជាមូលដ្ឋានសម្រាប់ក្រុមហ៊ុនធ្វើការវាយតម្លៃខ្លួនឯងក្នុងនាមជាក្រុមហ៊ុនផលិតក្រដាសសកលលោកល្បីមួយ ។ ក្រុមហ៊ុន APP បានដាក់ចេញនូវចក្ខុវិស័យ និងផែនទីបង្ហាញផ្លូវឆ្ពោះទៅរកនិរន្តរភាពសម្រាប់ឆ្នាំ២០២០ របស់ខ្លួន ដែលមានរួមបញ្ចូលគោលការណ៍របស់គ្លូបលកំផែកទៅក្នុងគោលដៅរយៈពេលខ្លី និងវែងរបស់ក្រុមហ៊ុនផងដែរ ។ ក្រុមហ៊ុន APP ដែលពឹងផ្អែកយ៉ាងខ្លាំងលើធនធានទឹក ក៏បានធ្វើការជាដៃគូជាមួយគ្លូបលកំផែក និងភាគីពាក់ព័ន្ធផ្សេងទៀតលើគម្រោងលើកស្ទួយគុណភាពធនធានទឹកក្នុងស្រុករបស់ក្រុមហ៊ុន ។ គម្រោងទាំងនេះបានជួយឱ្យការចាត់ចែងធនធានដើមមានលក្ខណៈល្អប្រសើរជាងមុនដែលជាកត្តាជួយឱ្យប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុនមានការរីកលូតលាស់ ។

## ប្រទេសថៃ

ទោះបីជាប្រទេសថៃមិនមានបណ្តាញក្នុងប្រទេសក្តី ក៏មានក្រុមហ៊ុនជាច្រើនបានចុះឈ្មោះជាមួយនឹងគ្លូបលកំផែក ក្នុងចំណោមក្រុមហ៊ុនទាំងនោះ ក្រុមហ៊ុនមួយនឹងលើកយកមករៀបរាប់បង្ហាញនៅខាងក្រោមនេះ ។

ក្រុមហ៊ុនបរទេសជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជាក្រុមហ៊ុនជីវវិទ្យាសាស្ត្របាយអូរេដ (Bio-Rad) ដែលមានស្នាក់ការកណ្តាលនៅរដ្ឋកាលីហ្វ័រញ៉ាបានទទួលការចោទប្រកាន់ក្រោមច្បាប់ស្តីពីការអនុវត្តពុករលួយនៅក្រៅប្រទេសពីបទសូកប៉ាន់មន្ត្រីនៅប្រទេសថៃដើម្បីទទួលបានកិច្ចសន្យាពាណិជ្ជកម្ម ។ ក្រុមហ៊ុន Bio-Rad នេះបានបង់ប្រាក់ពិន័យសរុបចំនួន៥៥លានដុល្លារសហរដ្ឋអាមេរិក។[7]

## សហជីពផលិតផលបង្កក់ថៃ (TUF)

សហជីពផលិតផលបង្កក់ថៃគឺជាក្រុមហ៊ុនផលិតផលិតផលគ្រឿងសមុទ្រដ៏ធំមួយនៅក្នុងពិភពលោក ដែលការលក់ប្រចាំឆ្នាំរបស់សហជីពនេះមានចំនួនលើសពី ២ពាន់លានដុល្លារសហរដ្ឋអាមេរិក ។ សហជីពផលិតផលបង្កក់ថៃបានចូលរួមក្នុងបណ្តាញគ្លូបលកំផែកនៅឆ្នាំ២០១៣ ។ យោងតាមបណ្ឌិត វីតស៊ូនតារាណាន់ នាយករបស់សហជីពផ្នែកនិរន្តរភាព បានឱ្យដឹងថាសហជីពនេះផ្តល់តម្លៃដល់ការអនុវត្តអន្តរជាតិល្អៗ ហើយបានប្រើប្រាស់

---

[7] ក្រុមហ៊ុន Bio-Rad បង់ប្រាក់៥៥លានដុល្លារដើម្បីជម្រះបញ្ចប់ទោសល្មើសនឹងច្បាប់ស្តីពីការអនុវត្តពុករលួយក្រៅប្រទេស http://www.fcpablog.com/blog/2014/11/3/bio-rad-pays-55-million-to-settle-fcpa-offenses.html



© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

បទពិសោធន៍ទាំងនោះសម្រាប់កែប្រែក្រមសីលធម៌ការងាររបស់ខ្លួន "ដើម្បីបំពេញនូវការរំពឹកទុករបស់ភាគីពាក់ព័ន្ធនានានៅគ្រប់ទីកន្លែង" ។ លើសពីនេះ លោក ធីវ៉ាផុង ចាន់ស៊ីរី នាយកប្រតិបត្តិរបស់សហជីពនេះបានទទួលស្គាល់ពីភាពចាំបាច់ក្នុងការលើកស្ទួយតម្លាភាពនៅក្នុងការងារ ដែលជាកត្តាសំខាន់ក្នុងការបង្កើនគុណតម្លៃធុរកិច្ចរបស់សហជីពជាពិសេសសម្រាប់ភាគីពាក់ព័ន្ធ ។ ការគោរពបានជាប់លាប់តាមគោលការណ៍ទាំងដប់របស់គ្លូបលកំផែកបង្ហាញឱ្យឃើញថាសហជីពផលិតផលបង្អែមមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្គត់ផ្គង់ផលិតផលមានគុណភាព និងបានបង្កើនភាពទាក់ទាញធ្វើឱ្យសហជីពក្លាយជាកន្លែងវិនិយោគមានសក្តានុពលមួយ ។ សហជីពផលិតផលបង្អែមបានទទួលស្គាល់ពីភាពចំបាច់ឱ្យមានតុល្យភាពរវាងការអភិវឌ្ឍធុរកិច្ច និងការអនុវត្តប្រកបដោយទំនួលខុសត្រូវដល់សង្គមរបស់សាជីវកម្ម ។ សហជីពនេះក៏បានទទួលស្គាល់ផងដែរថាខ្លួនសម្រេចបាននូវតុល្យភាពនេះ ។

# បញ្ហាប្រឈម

ទោះបីជាផលប្រយោជន៍ជាច្រើនអាចទទួលបានពីការអនុវត្តស្តង់ដារអន្តរជាតិទាំងនេះក្តី ក៏ក្រុមហ៊ុននៅតែអាចជួបប្រទះនឹងបញ្ហាប្រឈមផ្សេងៗ នៅពេលអនុវត្តស្តង់ដារ និងប្រព័ន្ធប្រឆាំងអំពើពុករលួយទាំងនេះដែរ ។

## សមត្ថភាពមិនគ្រប់គ្រាន់

ជាទូទៅក្រុមហ៊ុនបរាជ័យដោយសារមិនបានប្រគល់ឯកសាររបាយការណ៍គ្រប់គ្រាន់ដូចជារបាយការណ៍តាមដានពីដំណើរការ ដែលជាតម្រូវការសម្រាប់បន្តសមាជិកភាពរបស់គ្លូបលកំផែក ។ ឧទាហរណ៍ដូចនៅប្រទេសហ្វីលីពីន បណ្តាញគ្លូបលកំផែកក្នុងស្រុកចាប់ដំណើរការនៅឆ្នាំ២០០២ ដោយមានហត្ថលេខីចំនួន ១៥០ ។ ប៉ុន្តែ ពីរភាគបីនៃក្រុមហ៊ុនទាំងអស់នោះត្រូវបានលុបឈ្មោះចេញពីបណ្តាញដោយសារពួកគេមិនបានប្រគល់របាយការណ៍អំពីដំណើរការការងារ ។ ក្នុងឆ្នាំ២០១៥ បណ្តាញនេះមានក្រុមហ៊ុនតិចជាង ៦០ តែប៉ុណ្ណោះ។ ក្រុមហ៊ុនពាណិជ្ជកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យមអាចមិនមានធនធានសេដ្ឋកិច្ចគ្រប់គ្រាន់សម្រាប់ចំណាយលើការថែទាំ និងការចំណាយទូទៅពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងការប្រឆាំងការសូកប៉ាន់។ លើសពីនេះ ក្រុមហ៊ុនអាចនឹងត្រូវចំណាយច្រើនលើការអនុវត្តគោលការណ៍ទាំងអស់របស់គ្លូបលកំផែក ដោយសារមិនអាចសម្រេចជ្រើសរើសគោលការណ៍ណាមួយដើម្បីដាក់ជាអាទិភាពបាន ។ ក្នុងករណីនេះ ក្រុមហ៊ុនទាំងនោះគួរជ្រើសយកប្រព័ន្ធស្តង់ដារផ្សេងទៀតដូចជាប្រព័ន្ធBS 10500ដែលអាចបត់បែនបានតាមតម្រូវការ ទំហំ និងអាទិភាពរបស់ក្រុមហ៊ុន។

## កង្វះខាតឆន្ទៈ

ការប្រើប្រាស់ប្រព័ន្ធប្រឆាំងការសូកប៉ាន់ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ពីស្តង់ដារ ត្រូវបានគេមើលឃើញថាផ្តល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុនធំៗច្រើនជាងក្រុមហ៊ុនទំហំតូច ។ នេះជាការពិតជាពិសេសសម្រាប់សាជីវកម្មពហុជាតិដែលមានប្រតិបត្តិការអាជីវកម្មនៅក្នុងប្រទេសដែលមិនមានច្បាប់បញ្ញត្តិគ្រប់គ្រាន់ ។ ហេតុដូចនេះ វិញ្ញាបនបត្រស្តង់ដារអន្តរជាតិមានសារប្រយោជន៍ចំពោះក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់សាជីវកម្មពហុជាតិប្រភេទនេះច្រើនជាងចំពោះក្រុមហ៊ុនក្នុងស្រុក ។ ក្រុមហ៊ុនទាំងនេះជាទូទៅត្រូវធានាជូនភាគីពាក់ព័ន្ធថាប្រតិបត្តិការ


© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

របស់ខ្លួននៅក្នុងប្រទេសប្រភេទនេះមានសុចរិតភាព បន្តទទួលខុសត្រូវចំពោះសង្គម មិនមានការគេងប្រវ័ញ្ច និងមានសុវត្ថិភាព ។ នេះក៏ជាការធានាមួយសម្រាប់ក្រុមហ៊ុនមេខ្លួនឯង និងភាគីពាក់ព័ន្ធផងដែរ ។ ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុនក្នុងស្រុកអាចមានការប្តេជ្ញាចិត្តទាបពីព្រោះក្រុមហ៊ុនទាំងនេះមិនសូវទទួលសម្ពាធពីភាគីពាក់ព័ន្ធ ។ ផ្ទុយទៅវិញ ក្រុមហ៊ុនទាំងនេះទទួលសម្ពាធពីកត្តាខាងក្រៅដូចជាពីមន្ត្រីរដ្ឋាភិបាលឱ្យប្រព្រឹត្តអំពើពុករលួយទៅវិញ ។ យ៉ាងណាក៏ដោយ គួរកត់សម្គាល់ថាក្រុមហ៊ុនក្នុងស្រុកក៏អាចទាញយកអត្ថប្រយោជន៍ពីវិញ្ញាបនបត្រស្តង់ដារអន្តរជាតិដែរ បើសិនជាពួកគេមានគម្រោងធ្វើអាជីវកម្មជាមួយនឹងសាជីវកម្មពហុជាតិ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។ ក្រុមហ៊ុនក្នុងស្រុកអាចបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងការនាំចេញផលិតផលរបស់ខ្លួន បើសិនជាមានវិញ្ញាបនបត្របញ្ជាក់ពីស្តង់ដារអន្តរជាតិនេះ ។

## ការរួមបញ្ចូលស្តង់ដារមិនទាន់គ្រប់គ្រាន់

ក្រុមហ៊ុនដែលចុះហត្ថលេខាជាមួយនឹងគ្លូបលកំផែករបស់អង្គការសហប្រជាជាតិអាចបញ្ចូលស្តង់ដារមិនទាន់បានគ្រប់គ្រាន់ ទៅក្នុងកម្មវិធីទំនួលខុសត្រូវដល់សង្គមរបស់ខ្លួន ។ ក្រុមហ៊ុនអាចនៅមិនទាន់មានមូលដ្ឋានសម្រាប់វិធានការប្រតិបត្តិតាម ដើម្បីធ្វើសវនកម្មនៅឡើយ ។ ក្នុងករណីនេះ ប្រព័ន្ធគ្រប់គ្រងការប្រឆាំងការសូកប៉ាន់ផ្សេងទៀតដូចជា BS 10500 អាចជួយបានពីព្រោះថាការវាយតម្លៃកម្មវិធីត្រូវធ្វើជាមុនសិនមុននឹងអាចដំឡើងប្រព័ន្ធនោះបាន ។ ក្រៅពីនេះ បុគ្គលិកត្រូវដឹងពីការរួមបញ្ចូលស្តង់ដារនេះដើម្បីឱ្យពួកគេបានដឹងថាក្រុមហ៊ុនមានយន្តការសម្រាប់ប្រឆាំងការសូកប៉ាន់ ។ វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា នឹងជួយអប់រំបុគ្គលិកអំពីអត្ថប្រយោជន៍នៃការប្រព្រឹត្តត្រឹមត្រូវនៅកន្លែងការងារ បែបបទសម្រាប់ពួកគេអនុវត្តនៅពេលស្ថិតក្នុងឬត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើពុករលួយ និងវិធីកាត់បន្ថយហានិភ័យនៃការអនុវត្តធុរកិច្ចពុករលួយ ។

## ប្រទេសកម្ពុជា

ការចូលរួមអនុវត្តស្តង់ដារអន្តរជាតិប្រឆាំងការសូកប៉ាន់ ដូចជាស្តង់ដារគ្លូបលកំផែករបស់អង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជានៅមានកម្រិតទាបនៅឡើយ ។ ប្រទេសកម្ពុជាមិនមានបណ្តាញគ្លូបលកំផែកក្នុងស្រុក មានន័យថានៅមានឱកាសបង្កើតបណ្តាញនេះ។ បច្ចុប្បន្នមានតែក្រុមហ៊ុនកម្ពុជាចំនួន ២ ប៉ុណ្ណោះដែលស្ថិតនៅក្នុងបញ្ជីអ្នកចូលរួមក្នុងគ្លូបលកំផែករបស់អង្គការសហប្រជាជាតិ ដែលក្រុមហ៊ុន២ នោះមាន ក្រុមហ៊ុនឧស្សាហកម្មដឹកជញ្ជូន **តេង ត្រែនស្ពតធេសិន លីមីធីត** និងក្រុមហ៊ុនទូរគមនាគមន៍អចល័ត **អ៊ីហ្សីខម** ។ ក្រុមហ៊ុនសាខាដឹកជញ្ជូននិងឡជីស្ទិកកម្ពុជា **អាអឹមអេ គ្រុប** ក៏បានប្តេជ្ញាគាំទ្រដល់គ្លូបលកំផែកនេះផងដែល ។

គួរកត់សម្គាល់ថាប្រទេសកម្ពុជាអាចនៅមិនទាន់មានសវនករចេញវិញ្ញាបនបត្រត្រឹមត្រូវនៅឡើយដោយសារបច្ចុប្បន្ននេះការទាមទារឱ្យមានយន្តការប្រឆាំងការសូកប៉ាន់មានតិចតួច ។ ការបណ្តុះបណ្តាលសមត្ថភាពគ្រូបង្ហាត់ ឬទីប្រឹក្សាឱ្យចេះអនុវត្តស្តង់ដារថ្មីតឹងរឹង និងបង្កើតយន្តការប្រឆាំងការសូកប៉ាន់អាចនឹងចំណាយអស់ច្រើន ។



© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper

## អ៊ីហ្ស៊ីខម

អ៊ីហ្ស៊ីខមគឺជាសហគ្រាសធុនតូច និងមធ្យមឯកជនដែលផ្តល់សេវាទូរគមនាគមន៍អចល័ត និងមាននិយោជិតចំនួន ១៨០ ស្ថិតនៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងខែសីហា ឆ្នាំ២០១៤ ក្រុមហ៊ុននេះបានក្លាយជាក្រុមហ៊ុនដំបូងគេបង្អស់នៅកម្ពុជាដែលបានចុះហត្ថលេខាចូលរួមក្នុងគ្លូបលកំផែក ។ ក្នុងនាមជាសមាជិកបណ្តាញ អ៊ីហ្ស៊ីខមបានប្តេជ្ញាចិត្តអនុវត្តគោលការណ៍ទាំងដប់របស់គ្លូបលកំផែកនេះ ហើយបានប្រគល់របាយការណ៍អំពីដំណើរការការងារជារៀងរាល់ឆ្នាំ ដើម្បីតាមដានពីការវិវឌ្ឍរបស់ខ្លួន ។ ក្រុមហ៊ុននេះក៏បានជ្រើសរើសប្រធានគ្រប់គ្រងផ្នែកទំនួលខុសត្រូវចំពោះសង្គមរបស់សាជីវកម្ម សម្រាប់ទទួលបន្ទុកកិច្ចការនេះផងដែរ ។ អ៊ីហ្ស៊ីខម មានមោទនភាពចំពោះការដែលបានក្លាយជាក្រុមហ៊ុនដំបូងគេបង្អស់ក្នុងកិច្ចផ្តួចផ្តើមទំនួលខុសត្រូវដល់សង្គមរបស់សាជីវកម្មនៅកម្ពុជា ។ លក្ខណៈពិសេសរបស់អ៊ីហ្ស៊ីខមមួយនេះបានផ្លាស់ប្តូរមុខមាត់របស់ក្រុមហ៊ុន ដែលអាចទាក់ទាញអ្នកវិនិយោគមានសក្តានុពលឱ្យធ្វើការកត់សម្គាល់ ។ វិញ្ញាបនបត្រនេះបំពេញបន្ថែមលើស្តង់ដារអន្តរជាតិផ្សេងទៀតរបស់ក្រុមហ៊ុនដូចជា ស្តង់ដារISO9001:2008 ដែលជាប្រព័ន្ធគ្រប់គ្រងបង្កើតដោយអង្គការស្តង់ដារអន្តរជាតិ ។ អ៊ីហ្ស៊ីខមទទួលស្គាល់ពីភាពចាំបាច់នៃការបន្តពង្រឹង និងពិនិត្យប្រៀបធៀបការផ្តល់សេវារបស់ខ្លួនជាមួយនឹងកម្រិតស្តង់ដារអន្តរជាតិ ។ ស្តង់ដារទាំងនេះបង្កើតជាវេទិកាអន្តរជាតិសម្រាប់ក្រុមហ៊ុនធ្វើការប្រកួតប្រជែងជាមួយនឹងប្រទេសជាច្រើនផ្សេងទៀតនៅជុំវិញពិភពលោក ។

## សេចក្តីបញ្ចប់

ថ្វីត្បិតតែមានបញ្ហាប្រឈមដែលក្រុមហ៊ុនអាចនឹងជួបប្រទះក្តី ការអនុវត្តស្តង់ដារអន្តរជាតិប្រឆាំងការសូកប៉ាន់ទាំងនេះមិនមែនជាដំណើរការដែលមានលក្ខណៈតឹងរឹងនោះទេ ផ្ទុយទៅវិញវាគឺជាដំណើរការដែលអាចបត់បែនបាន ។ ទោះជាយ៉ាងនេះក្តី នៅពេលឥឡូវនេះការអនុវត្តស្តង់ដារអន្តរជាតិទាំងនេះត្រូវបានគេទទួលស្គាល់ថាមានសារប្រយោជន៍ចំពោះសាខាក្រុមហ៊ុនពហុជាតិនៅប្រទេសកម្ពុជាច្រើនជាងសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ។ មូលហេតុចម្បងនោះគឺដោយសារសហគ្រាសទាំងនេះមានធនធានតិចតួចដែលធ្វើឱ្យការដំឡើងប្រព័ន្ធទាំងនេះក្នុងសហគ្រាសមិនអាចទៅរួចបាន ។ ដូច្នេះកិច្ចប្រឹងប្រែងនាពេលបច្ចុប្បន្នគឺផ្តោតទៅលើការបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងរបស់សហគ្រាសធុនតូច និងមធ្យម អំពីជម្រើសក្នុងការដំឡើងស្តង់ដារទាំងនេះនៅក្នុងរចនាសម្ព័ន្ធក្រុមហ៊ុន ។ ប៉ុន្តែក្នុងរយៈពេលយូរអង្វែង នៅពេលវិស័យឯកជនរបស់ប្រទេសកម្ពុជាមានការរីកលូតលាស់ ក្រុមហ៊ុនអាចនឹងមានបំណងបញ្ចូលការអនុវត្តល្អៗរបស់ពួកគេទៅក្នុងទីផ្សារជាសកល ។ ក្រុមហ៊ុនបរទេសមកពីប្រទេសដែលមានច្បាប់ប្រឆាំងការសូកប៉ាន់តឹងរឹង ដូចជាសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេសនោះ ក៏អាចធ្វើការវិនិយោគកាន់តែច្រើនឡើងៗនៅក្នុងប្រទេសកម្ពុជាផងដែរ ។ ស្តង់ដារអន្តរជាតិនឹងមានសារសំខាន់ក្នុងការជំរុញឱ្យមានការវិវឌ្ឍឆ្ពោះទៅមុខនិងធានាដៃគូអន្តរជាតិថ្មីរបស់ប្រទេសកម្ពុជានូវកិត្តិសព្ទ និរន្តរភាព និងភាពជោគជ័យដែលកំពុងរីកធំធាត់របស់ប្រទេស ។



© 2014 Transparency International Cambodia. All rights reserved.
Printed on 100% recycled paper